**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧០ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការកាត់ដីនៅស្រុកទឹកឈូ ខេត្តកំពត ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៩៦៦២ កសក ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ១ ៧៧៦,៤០៣៤ ហិកតា ចេញពីដីតម្រូវព្រៃឈើឆ្នាំ២០០២និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ក្នុងនោះ ទំហំ ១៦២៤ ,៩៥៣៦ ហិកតា សម្រាប់ប្រទានកម្មនិងរក្សាទុកផ្ទៃដីទំហំ ១៥១,៤៤៩៨ ហិកតា ជាដីសាធារណៈរបស់រដ្ឋ នៅ ភូមិត្រពាំងកក់ ឃុំ ស្ទឹងកែវ ស្រុកទឹកឈូ ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពតដើម្បីធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៨៧ គ្រួសារ នៅភូមិត្រពាំងកក់ ឃុំ ស្ទឹងកែវ ស្រុកទឹកឈូ ខេត្តកំពត ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពតត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ......៤០ អនក្រ.បក......ចុះថ្ងៃទី...១០....ខែ...កុម្ភៈ...ឆ្នាំ ២០១៧/ស្ដីពី ការកាត់ចេញពីផែនទីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ ២០០២ ទំហំ១៧៧៦.៤០៣៤ ហិកតា នៅភូមិត្រពាំងកក់ ឃុំស្ទឹងកែវ ស្រុកទឹកឈូ ខេត្តកំពត ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៨៧ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



វាស់វែង ដោយប្រើឧបករណ៍ GPS MAP 62s

កំពត.ថ្ងៃទី..២៦......ខែ..កក្កដា..ឆ្នាំ២០១៦

អ្នកវាស់វែង

អ៊ិត ចាន់

លេខ.Ƙ៤២២.ដបគ៥

បានឃើញ និងពិនិត្យត្រឹមត្រូវ

កំពត.ថ្ងៃទី..២៧....ខែ..កក្កដា..ឆ្នាំ២០១៦

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត

ឃិន-ទុន្សា

លេខ.Ƙ១២១៦ ៧៩

បានឃើញ និងឯកភាព

កំពត.ថ្ងៃទី...០៣...ខែ...សីហា....ឆ្នាំ២០១៦

អភិបាលខេត្ត និងជា

ប្រធានគណៈកម្មការរៀបចំដែនដីរាជធានីខេត្ត

ចាន់ ចេស្តា

ឧបសម្ព័ន្ធ.............ចំណុចនិយាមកា ដីដែលស្នើសុំការកាត់ចេញពីដែនទឹកគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ ២០០២

នៅភូមិព្រពាំងពក់ ឃុំស្ទឹងកែវ ស្រុកទឹកឈូ ខេត្តកំពត ដើម្បីស្នើសុំធ្វើអនុបយោគនិងការធ្វើប្រទានកម្មដីជាកម្មសិទ្ធិ

ជូនប្រជាពលរដ្ឋកាន់កាប់ប្រើប្រាស់ជាក់ស្តែង

| ចំណុច | Y | X | ចំណុច | Y | X | ចំណុច | Y | X | ចំណុច | Y | X |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 1186113 | 409769 | 43 | 1187711 | 409104 | 85 | 1190220 | 407966 | 127 | 1193360 | 406998 |
| 2 | 1186264 | 409775 | 44 | 1187710 | 409099 | 86 | 1190225 | 407946 | 128 | 1193332 | 407180 |
| 3 | 1186550 | 409808 | 45 | 1187727 | 409083 | 87 | 1190281 | 407944 | 129 | 1193339 | 407272 |
| 4 | 1186645 | 409816 | 46 | 1187679 | 409052 | 88 | 1190316 | 407950 | 130 | 1193348 | 407427 |
| 5 | 1186648 | 409760 | 47 | 1187677 | 409030 | 89 | 1190329 | 407943 | 131 | 1193377 | 407526 |
| 6 | 1186650 | 409741 | 48 | 1187880 | 408857 | 90 | 1190325 | 407930 | 132 | 1193377 | 407636 |
| 7 | 1186617 | 409735 | 49 | 1187704 | 408863 | 91 | 1190318 | 407900 | 133 | 1193343 | 407832 |
| 8 | 1186619 | 409697 | 50 | 1187728 | 408873 | 92 | 1190307 | 407840 | 134 | 1193343 | 407949 |
| 9 | 1186643 | 409681 | 51 | 1187796 | 408864 | 93 | 1190322 | 407666 | 135 | 1193353 | 408040 |
| 10 | 1186646 | 409560 | 52 | 1187816 | 408841 | 94 | 1190335 | 407649 | 136 | 1193357 | 408100 |
| 11 | 1186659 | 409451 | 53 | 1187903 | 408811 | 95 | 1190440 | 407845 | 137 | 1193347 | 408301 |
| 12 | 1186697 | 409432 | 54 | 1188127 | 408693 | 96 | 1190453 | 407392 | 138 | 1193313 | 408442 |
| 13 | 1186689 | 409347 | 55 | 1188229 | 408674 | 97 | 1190461 | 407393 | 139 | 1193291 | 408541 |
| 14 | 1186682 | 409260 | 56 | 1188235 | 408657 | 98 | 1190497 | 407276 | 140 | 1193288 | 408575 |
| 15 | 1186688 | 409219 | 57 | 1188394 | 408650 | 99 | 1190497 | 407158 | 141 | 1193290 | 408647 |
| 16 | 1186737 | 409225 | 58 | 1188402 | 408779 | 100 | 1190520 | 407100 | 142 | 1193308 | 408740 |
| 17 | 1186759 | 409195 | 59 | 1188474 | 408777 | 101 | 1190521 | 407053 | 143 | 1193338 | 408884 |
| 18 | 1186856 | 409186 | 60 | 1188481 | 408732 | 102 | 1190516 | 406951 | 144 | 1193382 | 409065 |
| 19 | 1186914 | 409186 | 61 | 1188513 | 408746 | 103 | 1194404 | 406324 | 145 | 1193403 | 409243 |
| 20 | 1186923 | 409207 | 62 | 1188859 | 408769 | 104 | 1195297 | 405948 | 146 | 1193389 | 409372 |
| 21 | 1186939 | 409223 | 63 | 1188892 | 408884 | 105 | 1195649 | 406000 | 147 | 1193343 | 409338 |
| 22 | 1186981 | 409193 | 64 | 1189005 | 408879 | 106 | 1195496 | 406328 | 148 | 1193315 | 409395 |
| 23 | 1187037 | 409204 | 65 | 1189001 | 408742 | 107 | 1195312 | 406409 | 149 | 1193296 | 409435 |
| 24 | 1187019 | 409152 | 66 | 1189286 | 408663 | 108 | 1195232 | 406439 | 150 | 1193271 | 409447 |
| 25 | 1187059 | 409090 | 67 | 1189490 | 408617 | 109 | 1195132 | 406472 | 151 | 1193275 | 409397 |
| 26 | 1187103 | 409099 | 68 | 1189951 | 408446 | 110 | 1195009 | 406517 | 152 | 1193043 | 409377 |
| 27 | 1187131 | 409118 | 69 | 1189983 | 408394 | 111 | 1194824 | 406551 | 153 | 1193014 | 409414 |
| 28 | 1187146 | 409124 | 70 | 1190111 | 408338 | 112 | 1194788 | 406552 | 154 | 1192956 | 409417 |
| 29 | 1187173 | 409132 | 71 | 1190047 | 408257 | 113 | 1194681 | 406559 | 155 | 1192972 | 409224 |
| 30 | 1187261 | 409113 | 72 | 1190034 | 408254 | 114 | 1194507 | 406593 | 156 | 1192842 | 409166 |
| 31 | 1187269 | 409310 | 73 | 1190019 | 408217 | 115 | 1194449 | 406614 | 157 | 1192708 | 409175 |
| 32 | 1187492 | 409257 | 74 | 1190055 | 408191 | 116 | 1194389 | 406638 | 158 | 1192661 | 409244 |
| 33 | 1187618 | 409229 | 75 | 1190084 | 408160 | 117 | 1194350 | 406650 | 159 | 1192566 | 409441 |
| 34 | 1187632 | 409219 | 76 | 1190136 | 408119 | 118 | 1194307 | 406668 | 160 | 1192360 | 409551 |
| 35 | 1187646 | 409209 | 77 | 1190093 | 408037 | 119 | 1194202 | 406708 | 161 | 1192264 | 409659 |
| 36 | 1187662 | 409218 | 78 | 1190050 | 408025 | 120 | 1194094 | 406723 | 162 | 1192166 | 409668 |
| 37 | 1187692 | 409176 | 79 | 1190048 | 407985 | 121 | 1194000 | 406733 | 163 | 1192172 | 409780 |
| 38 | 1187693 | 409146 | 80 | 1190065 | 407966 | 122 | 1193967 | 406756 | 164 | 1192169 | 409831 |
| 39 | 1187701 | 409141 | 81 | 1190069 | 407929 | 123 | 1193890 | 406821 | 165 | 1192079 | 409810 |
| 40 | 1187697 | 409131 | 82 | 1190077 | 407921 | 124 | 1193816 | 406877 | 166 | 1192028 | 409826 |
| 41 | 1187710 | 409125 | 83 | 1190089 | 407930 | 125 | 1193759 | 406910 | 167 | 1192030 | 409775 |
| 42 | 1187717 | 409116 | 84 | 1190098 | 407950 | 126 | 1193687 | 406925 | 168 | 1191859 | 409775 |

វាស់វែង ដោយប្រើឧបករណ៍ GPS MAP 62s

កំពត.ថ្ងៃទី..២៦.......ខែ.តុលា..ឆ្នាំ២០១៦

អ្នកវាស់វែង

លេខ.៥២២.ឧបគភ អ៊ុក ចាន់

បានឃើញ និងពិនិត្យត្រឹមត្រូវ

កំពត.ថ្ងៃទី..២៧....ខែ.តុលា...ឆ្នាំ២០១៦

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត

លេខ.ស.១៤.១៦ ៧៨ យិន-ខុន្ឌ

បានឃើញ និងឯកភាព

កំពត.ថ្ងៃទី....០៣..ខែ...សីហា.....ឆ្នាំ២០១៦ ៧

អភិបាលខេត្ត និងជា

ប្រធានគណៈកម្មការរៀបចំដែនដីថ្នាក់ខេត្ត

ចាន់ ចេស្តា

N

មាត្រដ្ឋាន1:46,000

Coordinate System Projection UTM Zone 48N Map Datum:WGS84